សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៦៤៩
ចុះថ្ងៃទី២៥-៧-២០១១
សាលដីកា
លេខ: ១១ ក្រហញ
ចុះថ្ងៃទី២៨-០២-២០១២

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសឲ្យប្រើ តាមក្រឹត្យលេខ: ០៦ ក្រ ចុះថ្ងៃទី០៨-០២-១៩៩៣ បានបើកសវនាការជាសាធារណៈ នៅសាលាឧទ្ធរណ៍នា ថ្ងៃទី០៩-០២-២០១២ ដោយមានសមាសភាព ដូចតទៅ:

<u>សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ</u>

លោក [redacted] ជាប្រធាន

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

<u>តំណាងមហាអយ្យការ</u>

លោក [redacted] ជាព្រះរាជអាជ្ញា

<u>ក្រឡាបញ្ជីសវនាការ</u>

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងក្តីព្រហ្មទណ្ឌលេខ:៦៤៩ ចុះថ្ងៃទី២៥-៧-២០១១ រវាង:

-ជនជាប់ចោទឈ្មោះ: [redacted] ស៊ីណា ភេទប្រុស កើតឆ្នាំ១៩៨៦ ជាតិខ្មែរ កើត និងមានទីលំនៅសព្វថ្ងៃ [redacted] ស្រុកពាភាំង ខេត្តព្រៃវែង មុខរបរធ្វើស្រែ ឪពុកឈ្មោះ: [redacted]រ) ម្តាយឈ្មោះ: [redacted] (រ) នៅលីវ ទោសពីមុនគ្មាន។

<u>ត្រូវចោទពីបទ:</u> រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅ ភូមិមេលោង ឃុំព្រៃកស្មៀត ស្រុកពាភាំង ខេត្តព្រៃវែង កាលពីថ្ងៃទី២០-១១-២០១០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៥ នៃច្បាប់ស្តីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

-មានមេធាវី [redacted] ចន្ថា ជាមេធាវីការពារឲ្យជនជាប់ចោទឈ្មោះ: [redacted] ស៊ីណា ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ: [redacted] ណាត ភេទស្រី កើតឆ្នាំ១៩៩៥ ជាតិខ្មែរ កើត និងមានទីលំនៅសព្វភូមិមេលាង ឃុំព្រៃកស្មៀត ស្រុកពាភាំង ខេត្តព្រៃវែង។

## ឯរឿងហេតុមានដូចតទៅ:

តាមពាក្យបណ្តឹងចុះថ្ងៃទី២៣ ខែ១១ ឆ្នាំ២០១០ របស់ឈ្មោះ [redacted] ណាត បញ្ជាក់ថានៅថ្ងៃទី-២០-១១-២០១០ ម៉ោង ៦ និង៣០នាទីល្ងាច កូនរបស់ខ្លួនឈ្មោះ [redacted] ចន្ថា អាយុ១៨ឆ្នាំ បានចេញពីផ្ទះម្នាក់ឯងមកវាំនៅវត្តមេលាង ដោយស្លៀកខោខូវប៊យ ជើងវែងពណ៌ខ្មៅ រហូតដល់ម៉ោង៩យប់ កូនខ្លួនដើរមកផ្ទះដល់ចំនុចផ្ទះលោក [redacted] នី កូនខ្លួនអង្គុយលេងលើបង់ ស្រាប់តែឈ្មោះ [redacted] ស៊ីណា បានចាប់រំលោភសេពសន្ថវៈ កូនរបស់ខ្លួនរហូតបានសម្រេច ឥឡូវនេះកូនរបស់ខ្លួនមានឈាមធ្លាក់តាមទ្វារមាសយ៉ាងខ្លាំង។ សំណូមពររកយុត្តិធម៌ និងចាប់ជនល្មើសមកផ្តន្ទាទោសតាមច្បាប់។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ: ០៥ "ច" ព្រ.ទ ចុះថ្ងៃទី៣០-៦-២០១១ របស់សាលាដំបូងខេត្តព្រៃវែង ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១.កែប្រែបទចោទពី រំលោភសេពសន្ថវៈ ដែលផ្តន្ទាទោសតាមមាត្រា ៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ មកបទ: អំពើអាសប្រតាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ តាមមាត្រា ៤៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

២.ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ស៊ីណា ភេទប្រុស កើតឆ្នាំ១៩៨៦ ជនជាតិខ្មែរ ដាក់ពន្ធនាគារចំនួន ២៤ខែគត់គិតពីថ្ងៃឃុំខ្លួន។

ពីបទ: អំពើអាសប្រតាំងនឹងអនីតិជនអាយុក្រោម ១៥ឆ្នាំ កាលពីថ្ងៃទី២០ ខែ១១ ឆ្នាំ២០១០

សាលក្រមនេះប្រកាសជាសាធារណៈនៅថ្ងៃទី៣០-៦-២០១១ ចំពោះមុខមេធាវីការពារឲ្យជនជាប់ចោ, ជនជាប់ចោទ, ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

បានឃើញរបាយការណ៍ ចុះថ្ងៃទី១៧-១១-២០១១ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ។

បានឃើញសេចក្តីសន្និដ្ឋាន ចុះថ្ងៃទី១៨-១០-២០១១ របស់ព្រះរាជអាជ្ញាសាលាឧទ្ធរណ៍។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ស៊ីណា (អវត្តមាន)

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ណាត (អវត្តមាន)

-មេធាវី [redacted] ចន្ថា (វត្តមាន)

តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋាន

អង្គហេតុនេះ ការសម្រេចមានលក្ខណៈត្រឹមត្រូវ ការប្តូរបទចោទប្រកាន់មានលក្ខណៈត្រឹមត្រូវ នៅពេលសុំឲ្យសាលាឧទ្ធរណ៍តម្កល់សាលក្រមរបស់សាលាដំបូង។

មេធាវី [redacted] ចន្ថា ជាមេធាវីការពារឲ្យជនជាប់ចោទបានថ្លែងហេតុថា: នៅពេលនេះខ្លួនសុំឯកភាព និងសុំតម្កល់សាលក្រមរបស់សាលាដំបូងដដែល។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់មេធាវីការពារឲ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយ របស់ជនជាប់ចោទ /ꞵ-

-ក្រោយពីបានស្តាប់អំណានចម្លើយ របស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានពិនិត្យគ្រប់ឯកសារដែលពាក់ព័ន្ធ

-ក្រោយពីបានពិចារណាត្រឹមត្រូវហើយ

## សាលាឧទ្ធរណ៍

## យល់ឃើញថា

១.បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី៣០-៦-២០១១ របស់ឈ្មោះ [redacted] វែនណា ធ្វើឡើងក្នុង កំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបានយោងមាត្រា ៣៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២.តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] ស៊ីណា ថា: នៅថ្ងៃកើតហេតុ គឺថ្ងៃទី២០-១១-២០១០ វេលាម៉ោង ៩យប់ ខ្លួន និងឈ្មោះ [redacted] ចន្ទា បានធ្វើការអោបថើប សុំស្រឡាញ់គ្នាបន្ទាប់មកឈ្មោះ [redacted] ចន្ទា បានស្រាតខោ ហើយខ្លួនបានយកប្រដាប់ភេទរបស់ខ្លួន ដាក់លើប្រដាប់ភេទរបស់ ចន្ទា ពេលនោះឈ្មោះ [redacted] ចន្ទា បានឲ្យចាំបន្តិច ដើម្បីយកសំឡីអនាម័យចេញ គាប់ជួនមានមនុស្សមក ដល់ក៏បានលើកខោរៀងៗខ្លួន ដោយខ្លួនមិនបានធ្វើការចាប់រំលោភ ហើយជនរងគ្រោះក៏គ្មានស្រែក និង ប្រតាយប្រតប់គ្នាដែរ។

៣.ប៉ុន្តែតាមចម្លើយជនរងគ្រោះឈ្មោះ [redacted] ចន្ទា បានបញ្ជាក់ថា: នៅថ្ងៃកើតហេតុឈ្មោះ [redacted] ស៊ីណា បានចាប់សំរាតខោខ្លួនត្រឹមជង្គង់ ដោយគំរាមមិនឲ្យខ្លួនស្រែក និងធ្វើការវាយមកលើខ្លួន ហើយ បានយកប្រដាប់ភេទ មកដាក់លើប្រដាប់ភេទរបស់ខ្លួន និងធ្វើការរំលោភបានសម្រេច និងតាមលិខិត លេខ: ១៩-១១-២០១០ ចុះថ្ងៃទី២៣-១១-២០១០ របស់មន្ទីរពេទ្យខេត្តព្រៃវែងបានបញ្ជាក់ថា ជនរងគ្រោះ ពិតជាមានស្នាមរហែកដាច់ប្រាកដមែន។

៤.តាមអង្គហេតុដែលបានយល់ឃើញខាងលើ មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ស៊ីណា ពីបទ: រំលោភអនីតិជនអាយុក្រោម១៥ឆ្នាំ ប្រព្រឹត្តនៅ ភូមិមេលោង ឃុំព្រៃកស្មៀត ស្រុកពារាំង ខេត្តព្រៃវែង កាលពីថ្ងៃទី២០-១១-២០១០ តាមមាត្រា៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

៥.សាលក្រមព្រហ្មទណ្ឌលេខ: ០៥ "ច" ព្រ.ទ ចុះថ្ងៃទី៣០-៦-២០១១ របស់សាលាដំបូងខេត្ត ព្រៃវែង សម្រេចពុំត្រឹមត្រូវតាមអង្គហេតុ និងគតិច្បាប់ឡើង គប្បីបដិសេធចោល និងសម្រេចឡើងវិញ តាមបទចោទប្រកាន់ដែលបានយល់ឃើញខាងលើ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី៣០-៦-២០១១ របស់ឈ្មោះ [redacted] វែនណា ទុកជាត្រឹមត្រូវ តាមទំរង់នឹងគតិច្បាប់។

២-បដិសេធសាលក្រមព្រហ្មទណ្ឌលេខ: ០៥ "ច" ព្រ.ទ ចុះថ្ងៃទី៣០-៦-២០១១ របស់សាលាដំបូង ខេត្តព្រៃវែង ចោលជាអសារបង់។

៣.សម្រេចផ្តន្ទាទោសឈ្មោះ [redacted] ស៊ីណា ភេទប្រុស អាយុ ២៦ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០៦ឆ្នាំ

ពីបទ: រំលោភអនីតិជនអាយុក្រោម១៥ឆ្នាំ ប្រព្រឹត្តនៅ ភូមិមេលោង ឃុំព្រៃកស្បៀត ស្រុកពារាំង ខេត្តព្រៃវែង កាលពីថ្ងៃទី២០-១១-២០១០ តាមមាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

៤.បន្តឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] ស៊ីណា ជាបណ្តោះអាសន្នតាមច្បាប់ ។

៥-សាលដីកានេះប្រកាសជាសាធារណៈថ្ងៃទី២៨.០២.២០១២ កំបាំងមុខជនជាប់ចោទ និង ដើមបណ្តឹង បើកផ្លូវតវ៉ាតាមកំណត់ច្បាប់ ។

<u>សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និង កងកំលាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់។</u>

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted], [redacted] | ហត្ថលេខា [redacted] |

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"
ភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៤
ក្រឡាបញ្ជី
[redacted]

បានឃើញ
ប្រធានសាលាឧទ្ធរណ៍
[redacted]